# ធម្មកថា

## របស់ព្រះតេជព្រះគុណបណ្ឌិត ហុក-សាវណ្ណ
## អំពីសុជីវធម៌និងពាក្យថាសីលធម៌

**Website: www.hoksavann.org**

ថ្ងៃទី៧ វិច្ឆិកា ២០០៤

១- <u>អំពីពាក្យថាសុជីវធម៌</u> ៖

ពាក្យថាសុជីវធម៌ ប្រែថាធម៌ឬរបៀបរស់នៅសមរម្យ ។ បានសេចក្តីថា ការរស់នៅដឹងលក្ខណៈនៃសង្គម ហើយអនុវត្តតាមរបៀបបែបបទនៃសង្គមនោះ ។ សុជីវធម៌នៃជនជាតិនីមួយៗមានលក្ខណៈប្លែកគ្នា ស្របទៅតាមវប្បធម៌ទំនៀមទំលាប់នៃជាតិរបស់ខ្លួន ។ ប៉ុន្តែមានគោលមួយដូចគ្នា គឺការគួរសមនឹងគ្នាទៅវិញទៅមក នៅពេលប្រាស្រ័យទាក់ទងគ្នា ។ ពេលធ្វើខុសឆ្គងដល់ជនណាម្នាក់ដោអចេតនា ក្នុងរបៀបសុជីវធម៌របស់ខ្មែរ ក៏ដូចជាសុជីវធម៌របស់ជនជាតិបរទេស គេពោលពាក្យថាខ្ញុំសុំទោស ។ ឯអ្នកដែលត្រូវគេសុំទោស តែងមានសុជីវធម៌តបវិញថាមិនអីទេ ។ ឧទាហរណ៍នេះបញ្ជាក់ថា គេមានសុជីវធម៌ គឺការរស់នៅមានសភាពសមរម្យ ចេះអត់ឱនឲ្យដល់គ្នាទៅវិញទៅមក ។ អំពើគួរសមនឹងគ្នានេះ ជាប្រពៃណីដ៏ល្អរបស់មនុស្សជាតិ ដែលមានអារ្យធម៌ខ្ពស់ជាងសត្វតិរច្ឆាន ។ ដូចជាជនជាតិខ្មែរ តែងមានការគួរសមនឹងគ្នា នៅពេលជួបគ្នាលើកដៃសំពះសួរ ហើយពោលថាខ្ញុំសុំជំរាបសួរ ។ ឯអ្នកដែលគេលើកដៃសំពះ ក៏សំពះតបវិញហើយពោលថា លើកដៃថ្វាយព្រះ ។ លក្ខណៈនេះពុំមែនជាអំពើថោកទាប ឬមិនជឿនលឿននោះទេ តែជាអំពើរបស់ជនជាតិមានពូជអម្បូរថ្លៃថ្នូរខ្ពង់ខ្ពស់ជឿនលឿន ដែលផ្ទុយគ្នាអំពីការឥតពូជអម្បូរវិញទេ ។ កូនចៅប្រុសស្រីខ្មែរតែគោរពឪពុកម្តាយរបស់ខ្លួន គោរពចាស់ព្រឹទ្ធាចារ្យ គោរពព្រះសង្ឃព្រះពុទ្ធសាសនា ។ ការគោរពនេះ គឺការសំដែងការកោតក្រែងនិងមានភក្តីភាព ។ នៅកន្លែងជាច្រើនដែលត្រូវមានសុជីវធម៌ ដូចជាសុជីវធម៌ក្នុងពេលស្តាប់សន្និសិទអ្វីមួយ សុជីវធម៌ក្នុងពេលធ្វើពិធីកម្មក្នុងសាសនាជាដើម ។ នេះជាអត្ថន័យដោយសង្ខេបនៃពាក្យថាសុជីវធម៌ ។

២- <u>អំពីពាក្យថាសីលធម៌</u> ៖

ពាក្យថាសីលធម៌ ប្រែថាច្បាប់ដែលមានប្រក្រតីខាងល្អ បានដល់ច្បាប់សំរាប់រៀបចំចរិយាមារយាទឲ្យខ្ពង់ខ្ពស់ថ្លៃថ្នូរ គឺការពុំប្រព្រឹត្តធ្វើអំពើអាក្រក់ដោយកាយនិងវាចា ។ ពាក្យថាសីលធម៌នេះ បើតាមអត្ថន័យពួកបស្ចឹមប្រទេសឲ្យន័យថា សីលធម៌គឺជាវិទ្យាសាស្ត្រដែលបង្រៀនរបៀបអនុវត្តដោយជៀសវាងអំពើអាក្រក់ ។ សីលធម៌មានន័យជំរៅជាងសុជីវធម៌ គឺសីលធម៌មានន័យអនុវត្តផ្លូវកាយនិងវាចារបស់មនុស្សឲ្យបានល្អ ជៀសវាងការបៀតបៀនអ្នកដទៃ សីលធម៌របស់សាសនានៃសង្គមខ្លះ ហាមមិនឲ្យបៀតបៀននិងសម្លាប់មនុស្សជាតិទូទៅ តែសត្វតិរច្ឆានពុំហាមឡើយ ។ ចំណែកសង្គមអ្នកកាន់ព្រះពុទ្ធសាសនា ហាមទាំងមនុស្សទាំងសត្វមិនឲ្យសម្លាប់ ដូចបាននិយាយនៅក្នុងសិក្ខាបទទី១នៃសីល ៥ គឺជាសីលធម៌មានន័យទូលាយនិងមានកិរិតខ្ពស់ ។ ការពុំមានសីលធម៌ នាំឲ្យមនុស្សបៀតបៀនគ្នានិងបង្ហូរឈាមគ្នា ។ ការមានសីលធម៌ គឺការគោរពសិទ្ធិមនុស្សនេះឯង ។ នេះជាអត្ថន័យសង្ខេបនៃពាក្យថាសីលធម៌ ។៚